**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ : ០៧៦/២១ សជណ

ថ្ងៃ ពុធ ៩កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្តផ្តល់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ ជូនប្រជាពលរដ្ឋមានអាយុពី ១៨ ឆ្នាំឡើងទៅ និងកុមារ-យុវវ័យមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលខកខានមិនបានមកទទួលចាក់វ៉ាក់សាំង ឬ ទើបគ្រប់អាយុទទួលចាក់វ៉ាក់សាំង ក្រោយពេលបិទបញ្ចប់យុទ្ធនាការក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា កន្លងមក ដោយទទួលបានការប្រគល់ភារកិច្ចពីគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ** បានចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងកុមារ-យុវវ័យមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ សម្រេចបានស្ទើរតែ **100%** នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ក្នុងនោះ យុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ត្រូវបានបិទបញ្ចប់កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ និងយុទ្ធនាការចាក់វ៉ាក់សាំងជូនកុមារ-យុវវ័យមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នឹងត្រូវបិទបញ្ចប់នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ។

យ៉ាងណាមិញ **រដ្ឋបាលរាជធានីភ្នំពេញ** សង្កេតឃើញមានបងប្អូនប្រជាពលរដ្ឋ និងកុមារ-យុវវ័យមួយចំនួនតូចខកខានមិនបានអញ្ជើញមកទទួលវ៉ាក់សាំងក្នុងអំឡុងពេលយុទ្ធនាការ ដោយមូលហេតុផ្សេងៗ រួមមាន ជាប់អនុវត្តវិធានចត្តាឡីស័ក, មានបញ្ហាសុខភាពត្រូវព្យាបាល, មានធុរៈចាំបាច់ខានមិនបាន ឬ ទើបគ្រប់អាយុទទួលវ៉ាក់សាំង ក្រោយពេលបិទបញ្ចប់យុទ្ធនាការ ជាដើម។ ក្នុងន័យនេះ **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ** សម្រេចបន្តផ្តល់ជូនប្រជាពលរដ្ឋ និងកុមារ-យុវជនខាងលើនេះ អាចអញ្ជើញមកទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ **នៅតាមទីតាំងមន្ទីរពេទ្យបង្អែក ចំនួន ៨ ទីតាំង ដែលនៅជិតលំនៅឋាន ឬ មណ្ឌលរបស់លោកអ្នក រៀងរាល់ម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ៥:០០នាទីរសៀល ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់មានការជូនដំណឹងជាថ្មី៖**

| ល.រ | ឈ្មោះមន្ទីរពេទ្យបង្អែក | អាសយដ្ឋាន |
|---|---|---|
| ១ | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | ផ្លូវលេខ ១៣៤ កែងផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា |
| ២ | មន្ទីរពេទ្យបង្អែកចតុមុខ | ផ្លូវជាតិលេខ ៥ ភូមិ១៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ |
| ៣ | មន្ទីរពេទ្យបង្អែកដង្កោ | ផ្លូវលេខ ២១៧ ភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ |
| ៤ | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិនសែនសុខ | ផ្លូវសែនសុខ៥ ភូមិសែនសុខទី៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ |
| ៥ | មន្ទីរពេទ្យបង្អែកច្បារអំពៅ | ផ្លូវលេខ៣៦១ កែងផ្លូវលេខ ៦៣៨ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ |
| ៦ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ផ្លូវលេខ ៥៦K ភូមិត្រពាំងឈូក សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ |
| ៧ | មន្ទីរពេទ្យបង្អែកព្រែកព្នៅ | ភូមិពោធិ៍មង្គល សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ |
| ៨ | មន្ទីរពេទ្យបង្អែកសម្តេចឳ-សម្តេចម៉ែ | ផ្លូវជាតិលេខ ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ដោយឡែក ចំពោះប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងកុមារ-យុវវ័យមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលបានទទួលវ៉ាក់សាំងដូសទី១ រួចរាល់ហើយ ក្នុងអំឡុងពេលយុទ្ធនាការនាពេលកន្លងមក សូមបងប្អូនប្រជាពលរដ្ឋ និងមាតាបិតា-អាណាព្យាបាល **មេត្តារួសរាន់អញ្ជើញមក ឬ នាំយកបុត្រធីតាលោកអ្នក មកទទួលវ៉ាក់សាំងដូសទី២ រៀងរាល់ម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ៥:០០នាទីរសៀល តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងបណ្ណចាក់វ៉ាក់សាំង នៅតាមទីតាំងដែលបានអញ្ជើញមកទទួលវ៉ាក់សាំងដូសទី១ នាពេលកន្លងមក។**

ទន្ទឹមនឹងនេះ មុនពេលអញ្ជើញទៅទទួលវ៉ាក់សាំង ចំពោះប្រជាពលរដ្ឋ ឬ កុមារ-យុវវ័យទាំងឡាយណា ដែលមានបញ្ហាសុខភាព ដូចជា ក្ដៅខ្លួន ក្អក-កណ្ដាស់ ផ្ដាសាយ ពិបាកដកដង្ហើម ឬ រោគសញ្ញាផ្សេងទៀត សូមមាតាបិតា-អាណាព្យាបាល និងអ្នកពាក់ព័ន្ធ ប្រើប្រាស់តេស្ដរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដើម្បីបញ្ជាក់ពីស្ថានភាពសុខភាព និងលទ្ធផលតេស្ដអវិជ្ជមាន ស្របតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងសុខាភិបាល ឬ អញ្ជើញទៅយកសំណាកវិភាគរកមេរោគកូវីដ-១៩ នៅតាមទីតាំងយកសំណាករបស់រដ្ឋ ជាមុនសិន ចៀសវាងប៉ះពាល់ដល់ក្រុមគ្រូពេទ្យ និងប្រជាពលរដ្ឋដទៃទៀត។ ជាមួយគ្នានេះ ក្នុងអំឡុងពេលអញ្ជើញមកទទួលវ៉ាក់សាំង សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងឡាយ ចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងត្រូវប្រកាន់ខ្ជាប់នូវវិធានការ "**៣ ការពារ និង ៣ កុំ**" របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមបងប្អូនប្រជាពលរដ្ឋ មាតាបិតា-អាណាព្យាបាល និងសាធារណជន ជាពិសេសប្រជាពលរដ្ឋ និងកុមារ-យុវវ័យដែលមិនទាន់ទទួលបានវ៉ាក់សាំង ក្នុងមូលដ្ឋានរាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន និងរួសរាន់អញ្ជើញមកទទួលវ៉ាក់សាំងដោយឥតគិតថ្លៃ ឱ្យបានទាន់ពេលវេលា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
-គ.វ.ក-១៩
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
-រដ្ឋបាលខណ្ឌទាំង១៤
-មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ
*"ដើម្បីមុខការ"*
-គ្រប់ប្រព័ន្ធឃោសនា
*"ដើម្បីផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh